multicultural communication

REVIEWED September2004
NSWMulticulturalHealthCommunicationService

KHMER / ខ្មែរ
July 2001
[BHC-5915]

# សំនួររបស់ស្រ្តីស្តីពីការពន្លូតកូន

## Questions women ask about abortion

ការពន្លូតកូន (ការបញ្ចប់ការមានផ្ទៃពោះតាមវេជ្ជសាស្រ្ត) ជាវិធីវះកាត់សាមញ្ញមួយដែលវេជ្ជបណ្ឌិតធ្វើក្នុងប្រទេសអូស្ត្រាលី។ ជាទូទៅការពន្លូតកូនមានផ្តល់ជូននៅគ្រប់រដ្ឋតាមមន្ទីរពិនិត្យរោគ និងមន្ទីរពេទ្យនានា។

<u>តើការពន្លូតកូនត្រឹមត្រូវតាមច្បាប់ដែរឬទេក្នុងប្រទេសអូស្ត្រាលី</u> ?

ការពន្លូតកូនជាការធ្វើទៅត្រឹមត្រូវតាមច្បាប់បើកាលណាមានការយល់ព្រមពីស្រ្តីផ្ទាល់ខ្លួន និងធ្វើឡើងដោយវេជ្ជបណ្ឌិតដែលមានសញ្ញាប័ត្រ។ ទាល់តែវេជ្ជបណ្ឌិតនោះ (ឬនៅក្នុងរដ្ឋខ្លះវេជ្ជបណ្ឌិត២នាក់) មានជំនឿច្បាស់លាស់ដោយយោងទៅតាមសុភនិច្ឆ័យថា ការពន្លូតកូនជាភាពចាំបាច់សំរាប់ថែរក្សាស្រ្តីនោះកុំឲ្យមានគ្រោះថ្នាក់ដល់ជីវិត ឬសុខភាពរាង្គកាយ ឬសុខភាពខាងផ្លូវចិត្ត។ វេជ្ជបណ្ឌិតនោះពិចារណានូវវិស័យវេជ្ជសាស្រ្ត សេដ្ឋកិច្ច និងវិស័យក្នុងសង្គម។

<u>តើការពន្លូតកូនធ្វើពេលមានផ្ទៃពោះដល់ត្រឹមណា</u> ?

តាមធម្មតាក្រោយពីពេលមានផ្ទៃពោះបាន៦ទៅ១២អាទិត្យ យោងទៅតាមមន្ទីរពេទ្យនោះ ។ ក្នុងករណីខ្លះការពន្លូតកូនអាចធ្វើបានទោះមានផ្ទៃពោះច្រើនអាទិត្យជាងនេះក្តី ក៏ប៉ុន្តែលុះត្រាតែមានការពិនិត្យមើលយ៉ាងខ្លាំងជិតដល់ពីសេចក្តីត្រូវការនោះដោយវេជ្ជបណ្ឌិត ដែលអាចត្រូវឲ្យមានការពិភាក្សាជាមួយវេជ្ជបណ្ឌិតឯទៀតផង។ ស្រ្តីក៏គួរតែមានទទួលការផ្តល់ឱវាទត្រឹមត្រូវ ជាផ្នែកមួយរួមក្នុងការពិនិត្យមើលនោះដែរ។

<u>តើការវះកាត់នោះមានទាក់ទងដល់អ្វីខ្លះ</u> ?

ស្រ្តីនោះអាចជ្រើសរើសយកថ្នាំសន្លប់ស្ពឹកសំរាប់តែមួយផ្នែករាង្គកាយឬពេញខ្លួនទាំងមូល(local or a general anaesthetic), ឬការចាក់ថ្នាំរម្ងាប់ការឈឺចាប់(Sedation given by injection)។ ការចាក់ថ្នាំរម្ងាប់ការឈឺចាប់(Sedation) ធ្វើឲ្យស្រ្តីភាគច្រើនមានអារម្មណ៍ដូចគេងលក់ ហើយមិនចងចាំនូវវិធីវះកាត់នោះទេ។ វេជ្ជបណ្ឌិតបញ្ចូលសម្ភារៈមួយទៅក្នុងកស្បូន ហើយបូមអ្វីៗផ្សេងៗដែលមានក្នុងស្បូន។ វិធីនេះអស់រយៈពេលប្រហែល១០នាទី។

<u>បន្ទាប់មកតើយ៉ាងដូចម្តេចដែរ</u> ?

ក្រោយពីការសំរាកមួយរយៈ ទើបគេអនុញ្ញាតឲ្យស្រ្តីនោះទៅផ្ទះ។ ស្រ្តីនោះអាចមានការរមួលក្រពើរ ចេញឈាម ឬអារម្មណ៍អស់កម្លាំង ដូច្នេះវាជាការប្រសើរបំផុតដែលស្រ្តីនោះឈប់សំរាក១ថ្ងៃនៅផ្ទះ។

<u>តើតម្លៃនៃការពន្លូតកូនប៉ុន្មាន</u> ?

តម្លៃអាចមានការផ្លាស់ប្តូរ ក៏ប៉ុន្តែជាទូទៅ អ្នកដែលមានប័ណ្ណមេឌីឃែរអាចត្រូវបង់ពី១៣០ ទៅ១៨០ដុល្លាសំរាប់ការពន្លូតកូនដែលប្រើថ្នាំសន្លប់ឬស្ពឹកសំរាប់តែមួយផ្នែករាង្គកាយ(local anaesthetic) (ឬការចាក់ថ្នាំរម្ងាប់

ការឈឺចាប់ sedation), តែបើជ្រើសយកថ្នាំសន្លប់ឬស្ពឹកពេញ(a general anaesthetic) តម្លៃប្រហែល ៣៣៥ដុល្លា។

តើវិធីពន្លូតកូនមានគ្រោះថ្នាក់យ៉ាងណាខ្លះ ?
ការពន្លូតកូនជាវិធីមួយដែលផុតគ្រោះថ្នាក់បើកាលណាធ្វើឡើងដោយវេជ្ជបណ្ឌិតដែលមានការពិសោធន៍ក្នុងមន្ទីរពិនិត្យ ឬមន្ទីរពេទ្យ។ គ្រោះថ្នាក់មានតិចតួច ដូចជា ៖

- ការរលាកក្លាយ
  នេះជាគ្រោះថ្នាក់ដែលអាចកើតឡើងគ្រប់ការវះកាត់។ យ៉ាងណាក្តី តាមធម្មតាគេតែងចេញថ្នាំអង់ទីប៊ីយ៉ូទិច ដើម្បីបន្ថយគ្រោះថ្នាក់នេះ ហើយគេតែងតែប្រាប់ស្ត្រីពីរបៀបបន្ថយគ្រោះថ្នាក់កុំឲ្យមានរលាកក្លាយ ដោយការងូតទឹក"តាមផ្កាឈូក"(showers) តែមិនឲ្យមុជទឹកក្នុងអាង មិនឲ្យហែលទឹក មិនឲ្យរួមតណ្ហានិងមិនឲ្យប្រើសម្ភារៈម្យ៉ាងហៅ Tampons ចំនួន២អាទិត្យ។ ប្រសិនបើមានរលាកក្លាយកើតឡើង តាមធម្មតាការឆាប់ទទួលការព្យាបាលនឹងប្រាកដមិនឲ្យមានឥទ្ធិពលដល់ភាពមានកូនទៅអនាគតរបស់ស្ត្រីនោះ។
- ការធ្វើពន្លូតកូនឡើងវិញ
  នៅក្នុងចំណោម១០០នៃការពន្លូតកូន ការចេញឈាម ការឈឺពោះខ្លាំងឬគ្រុនក្តៅអាចកើតមានឡើងប្រសិនបើគេមិនបានយកអ្វីនៅក្នុងស្បូនចេញអស់។ ប្រសិនបើករណីនេះកើតឡើង ស្ត្រីនោះនឹងត្រូវការវិធីពន្លូតកូននេះជាលើកទីពីរ។
- កាស្នាមធ្លុះស្បូន
  នៅក្នុងចំណោម១ពាន់នៃការពន្លូតកូន មានស្នាមធ្លុះតូចមួយកើតឡើងដោយសារសម្ភារៈដែលគេប្រើ។ តាមធម្មតាស្នាមធ្លុះនោះតូច ហើយជាសះទៅវិញខ្លួនឯងដោយគ្មានបញ្ហាអ្វីទេ។ ប្រសិនបើវេជ្ជបណ្ឌិតសង្ស័យថាមានប៉ះខូចដល់ពោះវៀនស្ត្រីនោះ ស្ត្រីនោះនឹងត្រូវទៅមន្ទីរពេទ្យ។

តើការពន្លូតកូនបង្កើននូវគ្រោះថ្នាក់កើតជម្ងឺមហារីកដោះដែរឬទេ ?
គេគ្មានភស្តុតាងខាងវេជ្ជសាស្ត្រដែលបញ្ជាក់ថា ការពន្លូតកូនបង្កើននូវគ្រោះថ្នាក់កើតជម្ងឺមហារីកដោះនោះទេ។

តើស្ត្រីមានអារម្មណ៍យ៉ាងណាដែរក្រោយពីការពន្លូតកូន ?
អារម្មណ៍សោកសង្រេងនិងព្រួយបារម្ភណ៍ ព្រមជាមួយនិងការធូរស្បើយក្នុងចិត្ត អាចមានជាធម្មតាក្រោយពីការពន្លូតកូន។ យ៉ាងណាមិញប្រសិនបើដំណើរទុក្ខព្រួយមានខ្លាំង គេនឹងមានផ្តល់លទ្ធភាពឲ្យមានការពិនិត្យប៉ាន់ស្មានមើល និងការផ្តល់ឱវាទ។ ទោះបីស្ត្រីភាគច្រើនមិនមានបញ្ហាផ្លូវចិត្ត ការស្រាវជ្រាវបានបង្ហាញឲ្យឃើញថា បើស្ត្រីនោះទទួលការជំរុញពីអ្នកក្រៅក្នុងការសំរេចចិត្ត ស្ត្រីនោះច្រើនតែមានការពិបាក។ ស្ត្រីភាគច្រើនត្រូវការឱកាសដើម្បីពិចារណាក្នុងការជ្រើសរើស ហើយស្ត្រីត្រូវការការគាំទ្រនៅពេលដែលគេបានសំរេចចិត្ត។
តើត្រូវទៅកន្លែងណាសំរាប់យកពត៌មានបន្ថែមទៀត ?
វេជ្ជបណ្ឌិតរបស់អ្នក មណ្ឌលសុខភាពស្ត្រី ឬមន្ទីរគំរោងការណ៍គ្រួសារ (FPA ដែលពីដើមគេហៅថា Family Planning Clinics) អាចជួយអ្នកក្នុងការទាក់ទងមន្ទីរពេទ្យសំរាប់ការពន្លូតកូន ក៏ប៉ុន្តែអ្នកមិនចាំបាច់

ត្រូវការសេចក្តីសំរាប់បញ្ជូនទៅនោះទេ។ ឬមួយអ្នកអាចមើលក្នុងសៀវភៅទូរស័ព្ទ Yellow Pages ក្រោមចំណងជើង Pregnancy Termination Services ។

ប្រសិនបើអ្នកមានការពិបាកក្នុងការទូរស័ព្ទជាភាសាអង់គ្លេស សុំអ្នកទាក់ទងទៅផ្នែកផ្តល់អ្នកបកប្រែ Translating and Interpreting Service (អក្សរកាត់ **TIS**) លេខ 131 450។

អ្នកអាចយកពត៌មានផ្នែកសុខភាពបន្ថែមទៀតជាភាសាខ្មែរ ពីកំព្យូទ័រតាមរយៈ **Multicultural Communication website at http://mhcs.health.nsw.gov.au**